# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

## ខែតុលា-វិច្ឆិកា ឆ្នាំ២០១៧ / October-November 2017

## មាតិកា


| | ទំព័រ |
|---|---|
| ខ្លឹមសារសង្ខេប/Executive summary | ២ |
| ១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends | ៥ |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៨ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ១០ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១០ |
| ១.៧. វិស័យសំណង់/Construction | ១១ |
| ២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices | ១១ |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១១ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១១ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១១ |
| ៣. ឧបសម្ព័ន្ធ | ១៣ |

## ខ្លឹមសារសង្ខេប / Executive summary

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែតុលា ឆ្នាំ២០១៧ បានថយចុះក្នុងអត្រា **0,២%** ធៀបនឹងខែមុន ប៉ុន្តែកើនឡើង **២,១%** បើធៀបនឹង១២ខែមុន។ សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើនមានការថយចុះគួរឱ្យកត់សម្គាល់ធៀបនឹងខែកញ្ញាកន្លងទៅ ដូចជា សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង, សន្ទស្សន៍ថ្លៃសម្លៀកបំពាក់និងស្បែកជើង, សន្ទស្សន៍ថ្លៃគមនាគមន៍, និងសន្ទស្សន៍ថ្លៃអប់រំ។ ប៉ុន្តែបើធៀបនឹងខែដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួននៅតែបន្តកើនឡើង ក្នុងនោះសន្ទស្សន៍ថ្លៃដឹកជញ្ជូនបានកើនឡើងក្នុងអត្រា ៣,៧% ដែលកំណើននេះមានការថមថយមកវិញបន្តិចបើធៀបនឹងកំណើនក្នុងខែសីហា និងកញ្ញាកន្លងទៅ។

តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៧ អតិផរណាប្រចាំឆ្នាំ **(year on year)** អាចនឹងមាន អត្រា ១,៤% ឬអតិផរណាមធ្យមប្រចាំឆ្នាំ **(year average)** អាចនឹងមានអត្រា ២,៨%។

២. *ឥណទាន÷* គិតត្រឹមខែតុលា ឆ្នាំ២០១៧ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមាន ៦៥.៦៧៥ប៊ីលានរៀល មានកំណើនក្នុង១ខែប្រមាណ ១,៤% ក្នុងរយៈពេល១០ខែឆ្នាំ២០១៧នេះ, ក្នុងនោះឥណទានដល់វិស័យសេវាកម្មមានចំនួន ៣៥.២៦៣ប៊ីលានរៀល, វិស័យសំណង់ កសិកម្មនិងឧស្សាហកម្មមានចំនួន ១៧.៣១៦ប៊ីលានរៀល, និងគ្រឹះស្ថានហិរញ្ញវត្ថុ រូបវន្តបុគ្គល និងផ្សេងៗមានចំនួន ១៣.០៩៦ប៊ីលានរៀល។ ទោះជាមានកំណើន ឥណទានខ្ពស់ក្តី កម្ពុជានៅតែរក្សាបានអត្រាឥណទានមិនដំណើរការក្នុងកម្រិតទាបប្រហាក់ប្រហែលនឹងប្រទេសជិតខាងក្នុងតំបន់។ នៅដើមខែធ្នូ ឆ្នាំ២០១៧នេះ ធនាគារជាតិបានដាក់ឱ្យអនុវត្តប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ក្នុងគោលបំណងពង្រឹងបន្ថែមទៀតអំពីការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិនរបស់គ្រឹះស្ថានក្រោមឱវាទ។

*អត្រាការប្រាក់÷* អត្រាការប្រាក់ធនាគារពាណិជ្ជចំពោះកម្ចីជាប្រាក់រៀល និងដុល្លារស្មើនឹង ១៤,៤៩% និង១១,៧៩% បានថយចុះបន្តិចធៀបទៅនឹងដើមឆ្នាំ ប៉ុន្តែនៅតែមានអត្រាខ្ពស់នៅឡើយ។ បន្ទាប់ពីការដាក់ឱ្យអនុវត្តប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈរបស់គណៈកម្មការមូលបត្រកម្ពុជា ធនាគារជាតិបានចេញប្រកាសស្តីពីលក្ខខណ្ឌចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការដាក់ពាក្យចុះបញ្ជីលក់មូលបត្រលើផ្សារមូលបត្រកម្ពុជា ដែលនេះនឹងជួយជំរុញដល់មធ្យោបាយហិរញ្ញប្បទានផ្ទាល់ តាមរយៈការកៀរគរមូលធនពីសាធារណជន និងវិនិយោគិនផ្សេងៗ ជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុដែលមានលំហូរខ្ពស់ (high liquidity) និងអត្រាការប្រាក់ទាបជាងហិរញ្ញប្បទានប្រយោល។ លក្ខខណ្ឌទាំងនេះរួមមាន មូលនិធិផ្ទាល់សុទ្ធមានចំនួនយ៉ាងតិច ៦០ប៊ីលានរៀល, អនុវត្តបានពេញលេញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា, មានស្ថានភាពហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អ តាមរយៈការធ្វើចំណាត់ថ្នាក់ដោយធនាគារជាតិត្រឹមកម្រិតសុវត្ថិភាពចាប់ពី ២ឆ្នាំឡើង, និងមានការអនុញ្ញាតពីធនាគារជាតិជាដើម។ កត្តានេះក៏នឹងជួយពង្រឹងទំនុកចិត្តមហាជនចំពោះមូលបត្រនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើការបោះផ្សាយមូលបត្រផងដែរ។

*ការផ្គត់ផ្គង់រូបិយវត្ថុ÷* គិតត្រឹមខែតុលា រូបិយវត្ថុទូទៅ M2 បានកើនដល់ ៧០.២៥៨ប៊ីលានរៀល ដោយមានកំណើនជាមធ្យមប្រចាំខែ ២,០១% ក្នុងរយៈពេល១០ខែឆ្នាំ២០១៧នេះ (ឆ្នាំ២០១៦មានកំណើនមធ្យមប្រចាំខែ ១,៤០%), ក្នុងនោះ

ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានចំនួន ៥៨.៥៩១ប៊ីលានរៀល មានកំណើនជាមធ្យមប្រចាំខែ ២,០៣%។ កំណើនរូបិយវត្ថុទូទៅ M2 មានកំណើនខ្ពស់ជាងប្រទេសជិតខាងក្នុងតំបន់, ក្នុងឆ្នាំ២០១៦កន្លងទៅ រូបិយវត្ថុទូទៅ M2 នៃប្រទេសកម្ពុជាបានកើនឡើង ១៨,១% វៀតណាមបានកើនឡើង ១៣,៨% ថៃបានកើនឡើង ៤,៨% និងម៉ាឡេស៊ីបានថយចុះ ១,០%។

*អត្រាប្តូរប្រាក់ និងទុនបម្រុងជារូបិយប័ណ្ណបរទេស÷* ក្នុងខែវិច្ឆិកានេះ ប្រាក់រៀលបានកើនតម្លៃបន្តិច, គិតត្រឹមចុងខែវិច្ឆិកានេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារស្មើ ៤.០៣៥រៀល/ ដុល្លារ អត្រាខែតុលាស្មើ ៤.០៣៧រៀល/ ដុល្លារ និងអត្រាខែកញ្ញា ៤.០៥៣រៀល/ ដុល្លារ។ ជាទូទៅប្រាក់រៀលមាននិន្នាការឡើងថ្លៃនាចុងឆ្នាំរហូតដល់ខែមីនានៃឆ្នាំបន្ទាប់ ខណៈដែលមានតម្រូវការទូទាត់ជាប្រាក់រៀលច្រើនក្នុងការទិញលក់កសិផលពីកសិករនារដូវកាលប្រមូលផល និងតម្រូវការប្រាក់រៀលសម្រាប់ការបង់ពន្ធលើប្រាក់ចំណេញនាដើមឆ្នាំរបស់សហគ្រាសនានា ជាពិសេសសហគ្រាសបរទេសធំៗ។ ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០១៧នេះ ធនាគារជាតិបានទិញចូលនូវរូបិយប័ណ្ណដុល្លារអាមេរិកចំនួន ៨៥៦លានដុល្លារ។ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៧ ទុនបម្រុងជារូបិយប័ណ្ណបរទេសសុទ្ធមានចំនួន ៨,៤ប៊ីលានដុល្លារ បានកើនឡើង ៣៨,៤%ធៀបនឹង ១ឆ្នាំមុន។

៣. *ការនាំចូល÷* ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ ការនាំចូលមានចំនួន ១១.២៦២លានដុល្លារ បានកើនឡើង ១០,៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះការនាំចូលមុខទំនិញវាយនភ័ណ្ឌកើនឡើង ៥,៧% ការនាំចូលបរិក្ខារសំណង់កើនឡើង ១៤,១% ដោយឡែកការនាំចូលប្រេងឥន្ធនៈបានថយចុះ ២៩,៥%។ *ការនាំចេញ÷* ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ ការនាំចេញមានចំនួន ៩.១៦៩លានដុល្លារ បានកើនឡើង ៨,៦%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ក្នុងនោះការនាំចេញផលិតផលវាយនភ័ណ្ឌនិងស្បែកជើងកើនឡើង ៧,៩% និងការនាំចេញផលិតផលកៅស៊ូកើនឡើង ៧០,៧%។

៤. នៅខែតុលា ឆ្នាំ២០១៧ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលសរុបបានចំនួន ១.៣៨៦,៣ប៊ីលានរៀល គឺបានកើនឡើង ២១,៨% ធៀបនឹងខែមុន និងកើនឡើង ៤៤,៥% ធៀបនឹងខែតុលា ឆ្នាំ២០១៦ ដែលគាំទ្រដោយទាំងចំណូលពន្ធផ្ទាល់ ពន្ធប្រយោល ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស និងចំណូលមិនមែនសារពើពន្ធ។ រីឯការអនុវត្តចំណាយថវិកាសរុបបានចំនួន ១.៥១២,៤ ប៊ីលានរៀល គឺបានកើនឡើង ៥,៣% បើធៀបនឹងខែតុលា ឆ្នាំ២០១៦។

តុល្យភាពថវិកាចរន្តនៅខែតុលា ឆ្នាំ២០១៧ មានអតិរេកសាច់ប្រាក់ចំនួន ១៣៨,១៦ប៊ីលានរៀល ប៉ុន្តែតុល្យភាពថវិកាសរុបមានឱនភាពសាច់ប្រាក់ចំនួន ១២៦,០៩ប៊ីលានរៀល។ ជារួម ត្រឹម១០ខែ ឆ្នាំ២០១៧នេះ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៣.៨៨៥,០១ ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ចំនួន ៤៦៥,១៥ប៊ីលានរៀល។

៥. ក្នុងរយៈពេល១១ខែ ឆ្នាំ២០១៧នេះ ចំនួនគម្រោងវិនិយោគដែលបានអនុញ្ញាតមានចំនួន ១០៧គម្រោង, អាចបង្កើតការងារបាន ១២៨ពាន់នាក់, គិតជាទុនវិនិយោគ ៤.៨៦០លានដុល្លារ បានកើនឡើង ៧៣,៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះមានការកើនឡើងខ្លាំងលើការវិនិយោគក្នុងវិស័យសេវាកម្ម និងទេសចរណ៍។

៦. ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិសរុបមាន ៤.៣៣០ពាន់នាក់ បានកើនឡើង ១០,៤%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ចំនួនមកដល់នៃភ្ញៀវអន្តរជាតិមានបម្រែបម្រួលជារដូវកាល ដែលជាទូទៅមានការប្រែប្រួលតិចតួចចាប់ពីខែមេសាដល់ខែកញ្ញា ដោយសារលក្ខខណ្ឌអាកាសធាតុ និងមានកំណើនខ្ពស់ចាប់ពីខែតុលាដល់ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

៧. *សរុបរយៈពេល១១ខែ ឆ្នាំ២០១៧នេះ* សំណើសាងសង់សរុបមាន ៣.០៥២គម្រោង បានកើនឡើង៦៦៤គម្រោង ធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំមុន, គិតជាតម្លៃសាងសង់សរុប ៦.៤២៨លានដុល្លារ បានកើនឡើង ២២,៣%, ប៉ុន្តែគិតជាផ្ទៃក្រឡាសាងសង់សរុបមាន ១០.៧៤៦ពាន់ម៉ែត្រការ៉េ បានថយចុះ ៦,១%។

៨. *ថ្លៃប្រេងឆៅ* ក្នុងខែវិច្ឆិកានេះ ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេង Brent ថ្លៃ ៦៣,៦ដុល្លារ/ធុង និងប្រេង WTI ថ្លៃ ៥៧,៤ដុល្លារ/ធុង។ ការផ្គត់ផ្គង់ប្រេងរបស់ពិភពលោកមានកម្រិតទាបជាងតម្រូវការក្នុងពីរត្រីមាសចុងក្រោយនេះ ប៉ុន្តែគម្លាតនេះបានរីកធំក្នុងត្រីមាសទី៣ឆ្នាំ២០១៧។ ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧ កម្ពុជាបាននាំចូលប្រេងសាំង ៤៥១ពាន់តោន និងប្រេងម៉ាស៊ូត ១.០៦៣ពាន់តោន បានកើនឡើងរៀងគ្នា ១២,៧% និង២,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

*ថ្លៃអង្ករ* ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ *(១)អង្ករកម្ពុជា* អង្ករនាំចេញ(ខ្ទេច៥%) នៅតែរក្សាថ្លៃ ៤៣៥ដុល្លារ/តោន ចាប់តាំងពីខែកញ្ញាកន្លងមក។ *(២)អង្ករថៃ* អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤១២ដុល្លារ/តោន បានកើនឡើង ២០ដុល្លារ/តោនធៀបនឹងខែមុន។ *(៣) អង្ករវៀតណាម* អង្ករនាំចេញ (ខ្ទេច៥%)ថ្លៃ ៤00ដុល្លារ/តោន បានថយចុះប្រមាណ ៥ដុល្លារ/តោនធៀបនឹងខែមុន។

*ថ្លៃកៅស៊ូ* ទោះជាថ្លៃប្រេងឆៅនៅតែបន្តកើនឡើង ថ្លៃកៅស៊ូធម្មជាតិនៅតែថយចុះក្នុងខែវិច្ឆិកានេះ ក្នុងនោះ កៅស៊ូស្តង់ដារ TSR20ថ្លៃ ១.៤២០ដុល្លារ/តោន បានថយចុះ ១០ដុល្លារ/តោនធៀបនឹងខែមុន និងកៅស៊ូ SGP/MYSថ្លៃ ១.៥៧0 ដុល្លារ/តោន បានថយចុះ ៦0ដុល្លារ/តោនធៀបនឹងខែមុន។ យោងតាម Global Rubber Markets: ការធ្លាក់នេះគឺដោយសារ ថ្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារចិនបានធ្លាក់ថ្លៃជាបន្តបន្ទាប់ចាប់តាំងពីខែកក្កដាមក។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច នៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)




Source: Min. LMUC




Source: Ministry of Tourism




Source: Customs and Excise Dept.




Source: Customs and Excise Dept.




Source: MEF & Int.




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបំរុងបរទេស (Inflation, M2 and Foreign Reserve)

**Net Foreign Reserve (Mn US$)**




Source: NBC

**Inflation (Montly)**




Source: NIS

**Inflation (Annual)**




Source: NIS

**Inflation of Main Group Items (monthly)**




Source: NIS

**Inflation of main group Items (Year on Year)**




Source: NIS

**Broad Money M2 (Bn KHR)**




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)


















# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)




Source: NBC




Source: NBC




Source: NBC




Source: NBC




Source: NBC




*Source: Cambodia Securities Exchange*

# ការអនុវត្តថវិកា (Budget)

ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៦-២០១៧




Source: MEF

ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៦-២០១៧




ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៦-២០១៧




ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៦-២០១៧




ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៦-២០១៧




ការដកសាច់ប្រាក់គម្រោងទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៦-២០១៧



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

**រៀបចំដោយ**

**នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*
*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២*
*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*
*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*
*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*